**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ការិយាល័យអ្នកនាំពាក្យ**

# សេចក្តីបដិសេធ

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបដិសេធទាំងស្រុង ចំពោះការផ្សាយព័ត៌មានមិនពិតរបស់សារព័ត៌មាន ឌឹខេមបូឌាដេលី ខ្មែរ (The Cambodia Daily Khmer) នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ ដែលបានចោទប្រកាន់ដោយគ្មានមូលដ្ឋានមកលើ ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ឯកឧត្តម ម៉េង ហុង អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ពាក់ព័ន្ធអំពើពុករលួយបណ្តាលឱ្យបាត់បង់ថវិកាបេឡាជាតិសន្តិសុខសង្គម។

ការផ្សាយប្រឌិតនូវព័ត៌មានមិនពិតនេះ ធ្វើឱ្យមានការយល់ច្រឡំ ក្នុងចេតនាទុច្ចរិត ដើម្បីញុះញង់ មួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះ កិត្តិយស ដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ ឯកឧត្តម ហេង សួរ និង ឯកឧត្តម ម៉េង ហុង ដែលនេះជាទង្វើអគុណធម៌ គ្មានវិជ្ជាជីវៈ គ្មានក្រមសីលធម៌សារព័ត៌មាន និងគ្មានការទទួលខុសត្រូវសម្រាប់ការផ្សាយរបស់ខ្លួន។ ជានិច្ចកាល ឌឹខេមបូឌាដេលី ខ្មែរ បានផ្សព្វផ្សាយព័ត៌មានដែលខ្វះការស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយ គ្មានប្រភពច្បាស់លាស់ និងបំផ្លើសពីការពិតទាំងស្រុង។ ជាមួយនឹងការផ្សាយរបស់ ឌឹខេមបូឌាដេលី ខ្មែរ នៅលើបណ្តាញសង្គម Facebook ដែលតែងតែក្លាហានក្នុងការប្រឌិតព័ត៌មាន ហើយក៏ជាសារព័ត៌មានដ៏កំសាកក្នុងការទទួលស្គាល់កំហុសឆ្គងរបស់ខ្លួនផងដែរ។ សារព័ត៌មាន ឌឹខេមបូឌាដេលី ខ្មែរ ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានឱ្យបានត្រឹមត្រូវ និងកែតម្រូវការផ្សាយរបស់ខ្លួនជាបន្ទាន់។

ការិយាល័យអ្នកនាំពាក្យ សូមបញ្ជាក់ថា បេឡាជាតិសន្តិសុខសង្គមមាននីតិវិធីច្បាស់លាស់ ក្នុងការចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជន និងមានយន្តការទូទាត់ថ្លៃសេវាសុខាភិបាល ប្រកបដោយតម្លាភាព និងគណនេយ្យភាព តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធតាមដានវឌ្ឍនភាពសំណើសុំសេវាសាធារណៈ និងសំណើសុំចុះកិច្ចព្រមព្រៀង ឬទូទាត់ថវិកាពី ប.ស.ស. (Tracking System) កាលពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៤ ដើម្បីតាមដានវឌ្ឍនភាពនៃការទូទាត់សេវារបស់ខ្លួនថាកំពុងស្ថិតនៅក្នុងដំណាក់កាលណានៅក្នុងគេហទំព័រ https://tracking.mlvt.gov.kh/។ ជាមួយគ្នានេះ ក្រសួងក៏បានដាក់ឱ្យដំណើរការប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" និងប្រអប់បណ្តឹងអនាមិក ដើម្បីផ្តល់ភាពងាយស្រួលដល់សាធារណជន ក្នុងការទទួលបានការឆ្លើយតបរបស់ក្រសួងនូវចម្ងល់ ឬសំណើនានា ឬភាពមិនពេញចិត្ត ឬភាពមន្ទិលសង្ស័យ ឬប្តឹងបុគ្គលណាមួយដោយពុំមានតម្រូវឱ្យបង្ហាញអត្តសញ្ញាណរបស់ម្ចាស់បណ្តឹងនោះឡើយ តាមរយៈគេហទំព័រ https://feedback.mlvt.gov.kh ឬអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន និងកុំចែកចាយបន្តចំពោះអត្ថបទដែលគ្មានការពិត និងគ្មានវិជ្ជាជីវៈខាងលើនេះ។

ថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥

"បណ្តឹងអនាមិក"

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩